ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..........................

# សេចក្តីប្រកាសព័ត៌មាន
# អ្នកនាំពាក្យក្រសួងការពារជាតិ

នាថ្មីៗនេះ មានជនទុច្ចរិតមួយចំនួនបានបង្កើត Facebook បន្លំយករូបនាយទាហានមួយចំនួន ទៅប្រើប្រាស់ដើម្បីបង្ហោះរូបភាព និងខ្លឹមសារ ញុះញង់វាយប្រហារមកលើ រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងការពារជាតិបានចាត់ទុកថា សកម្មភាពទាំងនេះគឺជាអំពើខុសច្បាប់ ដែលមិនអាចអត់ឱនឱ្យបាន ហើយសូមស្នើឱ្យស្ថាប័នមានសមត្ថកិច្ច ចាត់វិធានការតាមផ្លូវច្បាប់ឱ្យបានម៉ឺងម៉ាត់បំផុត។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជម្រាបជូនថា កងយោធពលខេមរភូមិន្ទ រក្សាជំហរស្មោះត្រង់ការពាររាជរដ្ឋាភិបាលស្របច្បាប់ និងសុខសន្តិភាពរបស់ប្រជាពលរដ្ឋ។ កងយោធពលខេមរភូមិន្ទ ប្រឆាំងដាច់ខាតចំពោះការប៉ុនប៉ង បង្កភាពវឹកវរដល់សង្គម ក៏ដូចជាការបំផ្លាញដល់សន្តិភាពរបស់ប្រទេស។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមអំពាវនាវដល់ កងយោធពលខេមរភូមិន្ទទាំងអស់ មានការប្រុងប្រយ័ត្ន ក្នុងការប្រើប្រាស់បណ្តាញសង្គមនានា ដោយរក្សាការពារសន្តិសុខ ការងារសម្ងាត់ របស់អង្គភាព។ សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវមានទំនុកចិត្តមកលើកងយោធបលខេមរភូមិន្ទ ហើយសូមកុំចាញ់ឧបាយកល ក្រុមទុច្ចរិតទាំងនោះឱ្យសោះ៕

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩